**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០៤៦/២០ ក.ប/ស.ណ.ស.ខ.ល

# សេចក្តីណែនាំ

## ស្តីពី

## វិធានការចត្តាឡីស័កចំពោះកម្មករនិយោជិត នៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលបានឈប់សម្រាកក្នុងអំឡុងពេលបុណ្យចូលឆ្នាំ និងចូលបម្រើការងារវិញ

យោងសេចក្តីជូនដំណឹងលេខ០១៣/២០ ក.ប/ស.ជ.ណ.ខ.ល ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ ស្តីពីវិធានការបង្ការជំងឺកូវីដ-១៩ នៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ក្នុងអំឡុងពេលលើកការឈប់សម្រាកបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ២០២០ និងសេចក្តីជូនដំណឹងលេខ០១៤/២០ ក.ប/ស.ជ.ណ.ខ.ល ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ ស្តីពីការប្រើប្រាស់ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត និងការធ្វើការងារនៅក្នុងអំឡុងពេលការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេសក្នុងគោលដៅបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, និងលិខិតលេខ០៦៦ សខល ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ ស្តីពីវិធានការចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ លើកម្មករ កម្មការិនី ដែលនឹងវិលត្រឡប់ចូលបម្រើការងារវិញបន្ទាប់ពីពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ របស់ក្រសួងសុខាភិបាល នោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំដល់ម្ចាស់ ឬនាយក និងបងប្អូនកម្មករនិយោជិត នៃរោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបានឈប់សម្រាកក្នុងអំឡុងពេលបុណ្យចូលឆ្នាំ និងចូលបម្រើការងារវិញដូចខាងក្រោម៖

**១-ចំពោះម្ចាស់ ឬនាយករោងចក្រ នៅរាជធានីភ្នំពេញ ត្រូវ៖**

- រៀបចំបន្ទប់ដោយឡែកនៅក្នុងទីតាំងសមស្របមួយសម្រាប់ចុះវត្តមានកម្មករនិយោជិត ដែលបានវិលត្រឡប់ចូលបម្រើការងារវិញបន្ទាប់ពីឈប់សម្រាកពីការងារ
- ចាត់តាំងបុគ្គលិករដ្ឋបាលឱ្យរៀបចំបញ្ជីឈ្មោះកម្មករនិយោជិត ដែលបានវិលត្រឡប់ចូលបម្រើការងារវិញបន្ទាប់ពីឈប់សម្រាកពីការងារ ដើម្បីប្រគល់ជូនអធិការការងារនៅរៀងរាល់ថ្ងៃនៅម៉ោង ២ រសៀល
- ណែនាំកម្មករនិយោជិតឱ្យទៅពិនិត្យសុខភាពនៅមណ្ឌលត្រួតពិនិត្យសុខភាព តាមការណែនាំរបស់អធិការការងារ ក្នុងនោះ៖
  - ➢ កម្មករនិយោជិត ដែលត្រូវបានត្រួតពិនិត្យឃើញមានរោគសញ្ញាសង្ស័យ ត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័កកម្រិត២ ដើម្បីត្រួតពិនិត្យបន្ត



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

- ➢ កម្មករនិយោជិត ដែលត្រូវបានត្រួតពិនិត្យឃើញមិនមានរោគសញ្ញាសង្ស័យត្រូវដាក់ខ្លួនឱ្យនៅដាច់ដោយឡែកនៅកន្លែងស្នាក់នៅរបស់ខ្លួនចំនួន ១៤ថ្ងៃ តាមវិធានចត្តាឡីស័កនៅផ្ទះរបស់ក្រសួងសុខាភិបាល និងត្រូវរាយការណ៍ជូនរដ្ឋបាលរោងចក្រតាមទូរស័ព្ទអំពីស្ថានភាពសុខភាពរបស់ខ្លួនជារៀងរាល់ថ្ងៃ ដើម្បីរដ្ឋបាលរោងចក្ររាយការណ៍បន្តជូនក្រុមគ្រូពេទ្យនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ➢ កម្មករនិយោជិត ដែលមិនមានកន្លែងស្នាក់នៅដោយសារមូលហេតុណាមួយ ដូចជាមានសំណូមពរពីម្ចាស់ផ្ទះជួល ឬអ្នកស្នាក់នៅជាមួយ ដែលមិនទាន់អនុញ្ញាតឱ្យចូលស្នាក់នៅត្រូវជូនដំណឹងមកក្រុមគ្រូពេទ្យនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទំនាក់ទំនងបញ្ជូនទៅមណ្ឌលចត្តាឡីស័កកម្រិត១ ណាមួយ។

- មិនមានកាតព្វកិច្ច ផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតណាម្នាក់ដែលឈប់សម្រាកដោយឯកឯងគ្មានការអនុញ្ញាតពីនិយោជក ក្នុងរយៈពេលធ្វើចត្តាឡីស័កនេះឡើយ
- មានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលត្រឹមចំនួន ៧ថ្ងៃ ជូនកម្មករនិយោជិតណាម្នាក់ដែលឈប់សម្រាកដោយមានការអនុញ្ញាតពីនិយោជក ក្នុងរយៈពេលធ្វើចត្តាឡីស័ក។ ដោយឡែកកម្មករនិយោជិតដែលអវត្តមាន ដោយមានការអនុញ្ញាតរបស់និយោជកដោយសារមានធុរៈពិសេស ដូចជាប្រពន្ធឆ្លងទន្លេ ឬជីដូនជីតា ម្តាយឪពុក ប្តីប្រពន្ធ កូន ទទួលមរណភាពត្រូវទទួលបានប្រាក់ឈ្នួលចំនួន ១៤ថ្ងៃ ពេញដដែល
- បន្តតាមដានសុខភាព ផ្តល់ម៉ាស និងតម្រូវឱ្យពាក់ម៉ាសជាដាច់ខាតចំពោះកម្មករនិយោជិត ដែលទើបបញ្ចប់ការធ្វើចត្តាឡីស័ក ឬទើបចូលធ្វើការ។

**២-ចំពោះកម្មករនិយោជិត ដែលបម្រើការងារនៅតាមរោងចក្រ ក្នុងរាជធានីភ្នំពេញ ត្រូវ៖**

- បង្ហាញខ្លួននៅតាមរោងចក្រ និងផ្តល់ព័ត៌មានចាំបាច់ជាដាច់ខាតតាមការកំណត់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីរដ្ឋបាលរោងចក្រចុះវត្តមាន និងសហការអនុវត្តវិធានចត្តាឡីស័ករបស់ក្រសួងសុខាភិបាល
- ទៅពិនិត្យសុខភាពនៅមណ្ឌលត្រួតពិនិត្យសុខភាព តាមការណែនាំរបស់រដ្ឋបាលរោងចក្រស្របតាមការកំណត់របស់អធិការការងារ
- អនុវត្តវិធានចត្តាឡីស័កនៅតាមមណ្ឌលដែលបានកំណត់ ឬកន្លែងស្នាក់នៅរបស់ខ្លួន ចំនួន ១៤ថ្ងៃ តាមការកំណត់របស់ក្រុមគ្រូពេទ្យ ឬអាជ្ញាធរមានសមត្ថកិច្ច
- រក្សាទុក និងបង្ហាញលិខិតបញ្ជាក់ស្ថានភាពសុខភាពរបស់ខ្លួនដែលចេញដោយក្រុមគ្រូពេទ្យ ដើម្បីបង្ហាញជូនរដ្ឋបាលរោងចក្រ និងម្ចាស់ផ្ទះជួល
- រាយការណ៍ជូនរដ្ឋបាលរោងចក្រតាមទូរស័ព្ទ អំពីស្ថានភាពសុខភាពរបស់ខ្លួនរៀងរាល់ម៉ោង ៨ព្រឹក ដើម្បីរដ្ឋបាលរោងចក្ររាយការណ៍បន្តជូនគ្រូពេទ្យនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ទាក់ទងទៅក្រសួងសុខាភិបាលតាមរយៈលេខ ១១៥ ឬទូរស័ព្ទលេខ ០១២ ៨២៥ ៤២៤ ឬ ០១២ ៩៥៨ ១៧៩ ប្រសិនជាមានអាការៈសង្ស័យណាមួយ ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនៅកន្លែងស្នាក់នៅ ចំនួន ១៤ថ្ងៃនេះ
- ពាក់ម៉ាសជាដាច់ខាតនៅកន្លែងបម្រើការងារ បន្ទាប់ពីបញ្ចប់ការធ្វើចត្តាឡីស័កនៅផ្ទះ ១៤ថ្ងៃនេះ។

ក្នុងករណីកម្មករនិយោជិតណាម្នាក់មិនបានអនុវត្តតាមកាតព្វកិច្ចទាំង៧ចំណុចខាងលើ កម្មករនិយោជិតនោះ អាចត្រូវបានបញ្ឈប់ពីការងារ ដោយមិនមានការទូទាត់អត្ថប្រយោជន៍ពីនិយោជកឡើយ។

**៣-ចំពោះម្ចាស់ ឬនាយក និងកម្មករនិយោជិត រោងចក្រនៅតាមបណ្តាខេត្ត ក៏ដូចជាម្ចាស់ ឬនាយក និងកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថាន ក្នុងវិស័យផ្សេងទៀត ត្រូវសម្របសម្រួលការធ្វើចត្តាឡីស័កនៅតាមផ្ទះ ចំនួន ១៤ថ្ងៃនេះ ដោយ៖**

- កម្មករនិយោជិត ដែលឈប់សម្រាកដោយឯកឯងគ្មានការអនុញ្ញាតពីនិយោជកនឹងមិនទទួលបានប្រាក់ឈ្នួលឡើយ ក្នុងរយៈពេលធ្វើចត្តាឡីស័កនេះ
- កម្មករនិយោជិត ដែលឈប់សម្រាកដោយមានការអនុញ្ញាតពីនិយោជកនឹងទទួលបានប្រាក់ឈ្នួលត្រឹមចំនួន ៧ថ្ងៃ ក្នុងរយៈពេលធ្វើចត្តាឡីស័កនេះ។ ដោយឡែកកម្មករនិយោជិត ដែលអវត្តមានដោយមានការអនុញ្ញាតរបស់និយោជកដោយសារមានធុរៈពិសេស ដូចជា ប្រពន្ធឆ្លងទន្លេ ឬជីដូនជីតា ម្តាយឪពុក ប្តីប្រពន្ធ កូនទទួលមរណភាពត្រូវទទួលបានប្រាក់ឈ្នួលចំនួន ១៤ថ្ងៃ ពេញដដែល
- រួមគ្នាតាមដានសុខភាពបន្ត និងត្រូវពាក់ម៉ាសជាដាច់ខាតចំពោះកម្មករនិយោជិត ដែលទើបបញ្ចប់ការធ្វើចត្តាឡីស័ក ឬទើបចូលធ្វើការ
- កម្មករនិយោជិតណាម្នាក់ ដែលមិនសហការអនុវត្តវិធានចត្តាឡីស័ក ឬបំពានវិធានការខាងលើ ហើយបង្កជាការភ័យខ្លាចដល់កម្មករនិយោជិតដទៃផ្សេងទៀត អាចត្រូវបង្ខំឱ្យឈប់ពីការងារដោយមិនទទួលបានការទូទាត់អត្ថប្រយោជន៍អ្វីទាំងអស់ពីនិយោជក។

ម្ចាស់ ឬនាយករោងចក្រ ឬកម្មករនិយោជិតអាចសាកសួរព័ត៌មានបន្ថែមរៀងរាល់ម៉ោងធ្វើការ តាមរយៈលោកវេជ្ជបណ្ឌិត យី កន្និដ្ឋា ០១៧ ៣៧៧ ៣៧៧, លោក ខៀវ សារុធ ០១៧ ៥៦៧ ៨៨៧, លោក អ៊ូ រតនា ០៩២ ៨៨៨ ៥៨៥, និងលោក ម៉ាញ ណារិទ្ធ ០៨៧ ៥២៥ ៦៥៦។

ម្ចាស់ ឬនាយករោងចក្រ និងបងប្អូនកម្មករនិយោជិតទាំងអស់ ត្រូវអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*ថ្ងៃ សុក្រ ១០ កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣*

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២០*

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសុខាភិបាល

-ក្រសួង ស្ថាប័នពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

-រដ្ឋបាលរាជធានី-ខេត្ត

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-ឯកសារ កាលប្បវត្តិ

## ផែនការត្រៀមបម្រុងមណ្ឌលពិនិត្យសុខភាពទាំង ១០ និងបន្ទប់បម្រុងសម្រាប់កម្មកររោងចក្រ ដែលគ្មានផ្ទះស្នាក់នៅប្រមាណជា ៣០០០នាក់ នៅក្នុងគោលដៅរាជធានីភ្នំពេញ

| ឈ្មោះខ័ណ្ឌ | រោងចក្រសរុប | កម្មករសរុប | អវត្តមាន ៥% | កន្លែងស្នាក់នៅដោយឡែក (១បន្ទប់ ២០-២៥នាក់) | មណ្ឌលត្រួតពិនិត្យសុខភាព |
|---|---|---|---|---|---|
| **រាជធានី** | **674** | **314,541** | **15,726** | បម្រុង ១៣៨បន្ទប់=២៧៦០-៣៤៥០នាក់, រថយន្តកូរ៉េ ២០គ្រឿង | រថយន្តកូរ៉េ ៣០គ្រឿង ដើម្បីដឹកពីតាមរោងចក្រទៅមណ្ឌលត្រួតពិនិត្យ |
| ពោធិ៍សែនជ័យ | 280 | 145,166 | 7,258 | ១- វិទ្យាល័យជម្ពូវ័ន្ត (៥០បន្ទប់), ២-អនុវិទ្យាល័យគោកបញ្ជាន់ (៣៩បន្ទប់) | ១-សួនវឌ្ឍនៈ១, ២-សួនកាណាឌីយ៉ា, ៣-អនុវិទ្យាល័យគោកបញ្ជាន់ |
| ដង្កោ | 82 | 46,815 | 2,341 | | ៤-សួនវឌ្ឍនៈ២, ៥-អនុវិទ្យាល័យដង្កោ |
| កំបូល | 68 | 25,019 | 1,251 | | ៦-មណ្ឌលសុខភាពកំបូល, ៧-តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ |
| មានជ័យ | 109 | 42,325 | 2,116 | | ៨-បឋមសិក្សាភូមិឫស្សី |
| សែនសុខ | 76 | 21,351 | 1,068 | | ៩-Cambodian Textile Worldwide and Phnom Penh Work Co. Ltd |
| ព្រែកព្នៅ | 8 | 1,529 | 76 | | |
| ច្បារអំពៅ | 9 | 1,737 | 87 | | |
| ឫស្សីកែវ | 34 | 26,030 | 1,302 | ៣-វិទ្យាល័យឫស្សីកែវ (៤៩បន្ទប់) | ១០-វិទ្យាល័យឫស្សីកែវ |
| ទួលគោក | 1 | 1,413 | 71 | | |
| ចំការមន | 2 | 1,895 | 95 | | |
| ដូនពេញ | 2 | 38 | 2 | | |
| ជ្រោយចង្វារ | 1 | 1,209 | 60 | | |
| បឹងកេងកង | - | - | - | | |